## II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ៨៦ អនក្រ.បក
### ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
### អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

### សំរេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអង្គភាពនានារបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

### ជំពូកទី ២
### តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

មាត្រា ៣._

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មដាក់អោយដំណើរការកម្មវិធីការងារដីធ្លីតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍ ៖

១- រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ។

២- ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ លើគោលនយោបាយដីធ្លី ។

៣- លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសំរេច ។

៤- លើកគំរោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លីដាក់អោយដំណើរការអនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ ។

៥- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយប្រើប្រាស់ដីឲ្យបានសមស្រប និងមានសមធម៌ ។

៦- ជំរុញការចុះបញ្ជីដីធ្លី ជាប្រព័ន្ធទូទាំងប្រទេស ។

៧- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុ ជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យមានប្រសិទ្ធភាព ។

៨- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឲ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់ ។

៩- ធ្វើទំនាក់ទំនងដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ដើម្បីបំពេញការងារ ។

១០- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឲ្យបានគ្រប់គ្រាន់ ដើម្បីដំណើរការការងារដីធ្លី ។

១១- លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

១២- ស្នើផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

១៣- ជំរុញតាមដាន វាយតំលៃលើគំរោងការងារដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារ ។

មាត្រា ៤._

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយខែ តាមការអញ្ជើញ និងការដឹកនាំរបស់អគ្គលេខាធិការ ។

មាត្រា ៥._

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សានយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់គ្រោះរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញការងាររបស់ខ្លួន ។

មាត្រា ៦._

អគ្គលេខាធិការ មានសិទ្ធលើកសំណើជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិនិត្យ និងសំរេចលើសេចក្តីប្រកាសតែងតាំង ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៧._

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ក្រុមការងារនយោបាយ និងគតិយុត្ត

២- ក្រុមការងារបច្ចេកទេស

៣- ក្រុមការងារពង្រឹងស្ថាប័ន

៤- ក្រុមការងាររដ្ឋបាល

ក្រុមការងារនីមួយៗត្រូវបានដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៨._

ការបែងចែកលំអិតនៃភារកិច្ចបុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៩._

ក្រុមការងារនយោបាយនិងគតិយុត្ត មានភារកិច្ច ៖

- រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ
- ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី លើគោលនយោបាយដីធ្លី
- លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាកំណែទំរង់ដីធ្លី ដើម្បីពិនិត្យ និងសំរេច

- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយប្រើប្រាស់ដីធ្លីឲ្យបានសមស្រប និងមានសមធម៌
- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឲ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់
- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឲ្យបានគ្រប់គ្រាន់ ដើម្បីដំណើរការការងារដីធ្លី
- លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

មាត្រា ១០._

ក្រុមការងារបច្ចេកទេស មានភារកិច្ច ៖

- លើកគំរោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លី ដាក់ឲ្យដំណើរការអនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ
- ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធទូទាំងប្រទេស
- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យមានប្រសិទ្ធភាព ។

មាត្រា ១១._

ក្រុមការងារពង្រឹងស្ថាប័ន មានភារកិច្ច ៖

- ទំនាក់ទំនងដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ ដើម្បីបំពេញការងារ
- លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅជាពិសេសការងារដីធ្លី
- ពង្រឹងគណៈកម្មការដោះស្រាយបាតុភាពបញ្ហាទំនាស់ដីធ្លី ។

មាត្រា ១២._

ក្រុមការងាររដ្ឋបាល មានភារកិច្ច ៖

- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- កសាងគំរោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តន៍ថវិកា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំ និងសំរួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន

- តាមដានវាយតំលៃលើគំរោងការងារដីធ្លីដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារនេះ ។

មាត្រា ១៣._

អគ្គលេខាធិការដ្ឋានប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា លក្ខខ័ណ្ឌនៃពលកម្មការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ ពិសេសសំរាប់បើកជូនភ្នាក់ងារនៃមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមសំណើរបស់អគ្គលេខាធិការ ។

មាត្រា ១៤._

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្តល់មកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

ជំពូកទី ៣

អវសានប្បញ្ញត្តិ

មាត្រា ១៥._

ការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណូមពររបស់អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ១៦._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧._

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងសមាជិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

ហត្ថលេខា

អ៊ឹម ឈុនលឹម

★★★